# មនុស្សអាត្មានិយម

ក្រោយការនាំដំណើរទេសចរណ៍របស់ក្រុមរស្មី ខ្ញុំបានសម្រាកពីរបីថ្ងៃ។ មិនមែនអត់មាន Tour ចេញទេ តែខ្ញុំគ្មានអារម្មណ៍ចង់ចេញទៅណាសោះ។ ខ្ញុំឱ្យបុគ្គលិកធ្វើជំនួស។ ណាមួយទាំងនេះក៏ជាការងាររបស់បុគ្គលិកខ្ញុំដែរ។ ថ្ងៃនេះសុំធ្វើជាកូនល្អមួយថ្ងៃ។ ខ្ញុំមិនចង់ទៅក្រៅទេ គ្រាន់តែចង់នៅផ្ទះធ្វើការងារមួយចំនួន។ ខ្ញុំមានទម្លាប់ខ្វះរុក្ខជាតិមិនបាន។ ទម្លាប់នេះកើតមានឡើង តាំងពីពេលដែលខ្ញុំទៅនៅខេត្តសៀមរាបម្នាក់ឯង។ កុំថាខ្ញុំឆ្កួតអី! បើសិនជាដឹងថា ខ្ញុំធ្លាប់

និយាយជាមួយរុក្ខជាតិ។ ហេហេ... រុក្ខជាតិមិនចេះឆ្លើយតបទេ តែរុក្ខជាតិចេះស្តាប់យើងនិយាយមែនណា៎។ បើមិនជឿ សាកមើលទៅ! ពេលយើងនិយាយជាមួយរុក្ខជាតិ វានឹងផ្លាស់ប្តូរពណ៌របស់វាទៅតាមសាច់រឿង និងអារម្មណ៍របស់យើង។ ពេលខ្លះវាប្តូរទៅជាស្រស់ជាងមុន ឬពេលខ្លះវាក៏ដូរទៅជាពណ៌ស្រអាប់គ្មានពន្លឺ... ក្រៀមស្រពោន បើទោះជាយើងកំពុងតែស្រោចទឹកឱ្យវាក៏ដោយ។ ខ្ញុំគិតថារុក្ខជាតិ វាបានស្តាប់ឮ និងរួមសុខទុក្ខជាមួយខ្ញុំពិតមែន... តែរឿងនេះ ខ្ញុំនៅតែពិបាកវែកញែកថា វាជាអារម្មណ៍របស់ខ្ញុំ ឬក៏ជាការប្រែប្រួលពិតរបស់ធម្មជាតិនោះទេ។ ខ្ញុំគ្រាន់តែដឹងថា អ្វីដែលល្អនោះគឺ វាបានជួយឱ្យខ្ញុំបានធូរស្រាលបន្ទាប់ពីបានខ្ជាក់ពាក្យក្នុងចិត្តចេញដោយមិនចាំបាច់និយាយទៅកាន់នរណាម្នាក់... ហើយខ្ញុំមិនចាំបាច់ខ្វល់ថាតើវានឹងបរិហាររឿងខ្ញុំ បន្ទាប់ពីខ្ញុំនិយាយប្រាប់វាឬអត់។ យករុក្ខជាតិជាមិត្តគឺល្អណាស់... ព្រោះវាមិនត្រូវការប្រយោជន៍ពីខ្ញុំក្រៅពីការស្រោចទឹកតែប៉ុណ្ណឹង។

«ផានុ!»

«បាទម៉ាក់!»

## ជីវភាពឯកា

«ស្រោចទឹករុក្ខជាតិឬអីកូន? បើស្រោចម្លឹងៗងាប់វាហើយ ស្រោចទាល់តែបែកភក់អស់ហើយកូននេះ!»

«អំ! ខ្ញុំអាល័យតែក្លឹកបន្តិចហ្នឹងណ៎ាម៉ាក់។ ហិហិ...»

«កូននេះ! មើល៍! ស្រោចប៉ុណ្ណឹងបានហើយ! ចូលផ្ទះវិញ ក្តៅណាស់កូន!»

«បាទម៉ាក់!»

ខ្ញុំមួរទុយយោទឹក ហើយយកទៅទុកនៅកន្លែងរ៉ូប៊ីណេរួចដើរចូលទៅក្នុងផ្ទះតាមសម្តីរបស់ម៉ាក់ខ្ញុំ។ ម៉ាក់ឈរចាំឱ្យតែខ្ញុំដើរចូលដល់ក្នុងផ្ទះនឹងអាលតែផ្តើមសន្ទនា។ ខ្ញុំចង់គេចគាត់ដែរ តែមើលទៅបែបគេចមិនរួចទេដឹង?

«ផានុ! មកនេះ ម៉ាក់មានរឿងចង់និយាយណ៎ាកូន!»

«បាទម៉ាក់! តែ... បើនិយាយរឿងនោះ ម៉ាក់កុំនិយាយអី!»

«កូនឯងដូចដឹងចិត្តម៉ាក់! តែម៉ាក់មិននិយាយ មិនបានឡើយ។» ម៉ាក់ខ្ញុំឆ្លើយទាំងសង្កត់សំឡេង បង្ខំផងលួងផង ហើយទាញដៃខ្ញុំទៅអង្គុយក្បែរគាត់។

«ម៉ាក់… ក្រុមហ៊ុនកូនទើបតែបើកទេ កុំប្រញាប់គិតគូររឿងមួយនោះអី។»

«ក្រុមហ៊ុនកូនទើបបើកមែន តែដំណើរការទៅល្អណាស់។ ម៉ាក់ខ្លាចលីណាបានគេ!»

«ម៉ាក់! តែខ្ញុំនិងលីណាមិនមានអីលើសពីមិត្តទេ។»

«តែចិត្តលីណា ម៉ាក់មើលធ្លុះ! នាងពេញចិត្តកូនណ៎ា! ហើយនាងជានារីល្អទៀត មារយាទល្អ ពូកែទាំងការងារក្រៅនិងក្នុង។»

«ម៉ាក់ប៉ុណ្ណឹងបានហើយ! ម៉ាក់កុំបង្ខំខ្ញុំ! ខ្ញុំសុំពេលនៅម្នាក់ឯងមួយរយៈទៀតសិន។» និយាយបានតែប៉ុណ្ណឹងខ្ញុំក៏គេចចេញ មិនឱ្យម៉ាក់បានឱកាសនិយាយអីទៀតបានទេ។

«កូន! ផានុ!» ម៉ាក់តាមហៅ តែខ្ញុំមិនឈប់។

បន្លប់ចិត្តកុំឱ្យសៅហ្មងរឿងដែលម៉ាក់បង្ខំ ខ្ញុំខំទាញសៀវភៅមកអាន តែ… អានមិនចូលសោះ។ ខ្ញុំក៏យកទូរសព្ទមកឆែកបណ្ដាញសង្គមលេងជំនួស។ គ្រាន់តែបើក online ភ្លាមរស្មីឆាតមកភ្លែត។

## ជីវភាពឯកា

«សួស្តីបងផានុ! សុខសប្បាយទេបង?»

«សួស្តីរស្មី! បាទសុខសប្បាយទេ។»

«កំពុងធ្វើអីហ្នឹង?»

«អត់ធ្វើអីទេ។ នៅផ្ទះអផ្សុកបន្តិច។»

«អីក៏ដូចគ្នាម្ល៉េះ? ខ្ញុំក៏អផ្សុកដែរ។»

«អ៎! អ៊ីចឹងហេតុអីរស្មីមិនចេញក្រៅ?»

«បងផានុបបួលខ្ញុំចេញក្រៅមែនទេ?»

«អ្ហាះ?...»

«អូខេណា! ល្ងាចនេះជួបគ្នាទៅ?»

ខួរក្បាលរបស់ខ្ញុំដូចជាចង់វិលក្បុងដោយសាររស្មី។ ខ្ញុំគ្រាន់តែសួរនាងទេតើ! ម៉េចក៏ទៅជាខ្ញុំបបួលនាងទៅវិញ? ហើយខ្ញុំគួរតែឆ្លើយទៅនាងយ៉ាងម៉េចទៅ?

«បងផានុ! អ៊ីចឹងជួបគ្នានៅ Sky Bar ចុះណ៎ា។ ម៉ោង៧ ជួបគ្នា។ មិនជួបមិនបែក!...»

ចុម! នាងលេងមែនទែនហើយអ៊ីតើ។ ខ្ញុំមិនគួរប្រកែកឱ្យនាងបាក់មុខទេ។ ណ្ហើយ! ទៅក៏ទៅ! ព្រោះខ្ញុំពេលនេះ ក៏មិនចង់នៅផ្ទះដែរ។

ម៉ោងណាត់មកដល់ខ្ញុំនៅអង្គុយចាំរស្មីនៅតុអាហារក្រៅជំបូល។ មើលទៅដូចជារ៉ូមែនទិកគួរសម។ ១៥នាទីហួសទៅ លេចរូបស្រីស្អាតម្នាក់ក្នុងសម្លៀកបំពាក់សិចស៊ីទាក់ភ្នែកឈរចំពោះមុខខ្ញុំ។ រស្មីស្លៀករ៉ូបខ្មៅត្រឹមក្បាលជង្គង់ ដៃតូច កជ្រៅ មើលទៅគួរឱ្យទាក់ទាញណាស់ វត្តមានរបស់រស្មីធ្វើឱ្យអ្នកអង្គុយនៅតុជិតៗនេះ មើលមកតុខ្ញុំមិនឈប់។ ប្រហែលខ្ញុំនេះ ជាបុរសដែលសំណាងនៅក្នុងរាត្រីនេះហើយទេដឹង?

«សុំទោសណ៎ាបង! ខ្ញុំមកយឺត១៥នាទីហើយ។» រស្មីបង្ហាញទឹកមុខអង្វរករ ខ្លាចខ្ញុំខឹងនាង។

«អ៊ូ! មិនអីទេ។ ខ្ញុំទើបតែមកដល់ដែរហ្នឹង។»

«បងហៅអីញ៉ាំហើយឬនៅ?»

«អ៊ំ! មិនទាន់ទេ។»

«អ៊ីចឹងឱ្យខ្ញុំជាអ្នកកុម្ម៉ង់បានទេ? ថ្ងៃនេះខ្ញុំចង់ញ៉ាំរបស់ពីរមុខ តែខ្ញុំញ៉ាំម្នាក់ឯងមិនអស់ទេ។ បងជួយញ៉ាំខ្ញុំណ៎ា?»

ខ្ញុំបានត្រឹមតែងក់ក្បាលមើលកាយវិការម៉ិកម៉ូក់របស់រស្មី។ នាងស្អាតណាស់! ហើយគួរឱ្យស្រលាញ់ទៀតផង។ ថ្ងៃនេះនាងចម្លែកណាស់! បង្ហាញភាពស្និទ្ធស្នាលដែលខ្ញុំ

## ជីវភាពឯកា

មិនធ្លាប់រំពឹងទុកសោះ។ ក្រោយញ៉ាំស្រាក្រហមអស់ពីរកែវ រស្មីដូចជាទោរទន់ដល់ហើយ។

«រស្មី! ស្រវឹងទេដឹង?»

«អត់ទេបង! ស្រវឹងអីងាយៗ។ ខ្ញុំសូមញ៉ាំមួយកែវទៀតណា។ បងកំដរខ្ញុំបានទេ?»

«បាទ! បាទ!» ខ្ញុំមិនដឹងប្រកែកស្រីស្អាតដោយវិធីណាទេ។

រស្មីយប់នេះពិតជាគួរឱ្យទាក់ភ្នែកណាស់។ បេះដូងរបស់ខ្ញុំលោតមិនឈប់ព្រោះតែភាពម៉្ញិកម៉ូក់ និងភាពសិចស៊ីរបស់នាង។ កាន់តែស្រវឹងកាន់តែសិចស៊ី។ ខ្ញុំស្ទើរតែទប់ចិត្តមិនបានទៅហើយ។ ស្រាក្រហមមួយដប បើខ្ញុំមិនដណ្តើមនាងញ៉ាំទេ រស្មីសឹងតែញ៉ាំម្នាក់ឯងអស់។ តើនាងមានទុក្ខលំបាកអ្វីបានជាចង់ញ៉ាំឱ្យស្រវឹង? តែនាងមិនគួរទុកចិត្តខ្ញុំពេកទេ ព្រោះនេះទើបតែជាការណាត់ជួបលើកទីមួយរបស់ពួកយើងតែប៉ុណ្ណោះ។ ឬនាងមានគម្រោងអ្វីទេដឹង?

«រស្មី! ស្រវឹងហើយ! មានជិះអីមកទីនេះទេ?»

«អត់ទេ! ខ្ញុំជិះតាក់ស៊ីមក។ បងជូនខ្ញុំទៅផ្ទះផង។»

«អ៎! បាទ! ចាំខ្ញុំជូនទៅ។»

ក្រោយគិតលុយរួច ខ្ញុំគ្រាស្រីស្អាតចូលទៅក្នុងឡាន។ ដងខ្លួនរបស់រស្មីទន់ទៅតាមការទាញរបស់ខ្ញុំ។ ខ្ញុំដើរស្ទើរតែមិនដល់ឡាន។ តាមពិតនាងដូចជាមិនពូកែញ៉ាំស្រាអីផង។ ដាក់នាងឱ្យអង្គុយស្រួលបួលហើយ ខ្ញុំក៏ចូលកាន់ចង្កូតឡាន។

«អ្ហេ! ផ្ទះរស្មីនៅឯណា?»

«ផ្ទះខ្ញុំនៅកន្លែងណាដែលមានបង។»

«អ្ហាករស្មី! និយាយអីហ្នឹង?»

ខ្ញុំអើយចប់ហើយ! មិនដឹងថាជាសំណាងឬជាកម្មទេ។ នាងនិយាយលែងដឹងអី ស្រាប់តែមកឱបកខ្ញុំដោយអំណាចស្រា។ តើខ្ញុំគួរតែយកនាងទៅណាទៅ? ពិបាកបើកឡានណាស់ ព្រោះនាងឱបខ្ញុំមិនលែង ថែមទាំងនិយាយថាស្រលាញ់ខ្ញុំទៀតផង។

«រស្មី! ដឹងខ្លួនឡើង។ ផ្ទះនៅឯណាប្រាប់មក ខ្ញុំជូនទៅ។»

«បងផានុ! ខ្ញុំស្រលាញ់បងណាស់។ ស្រលាញ់តាំងពីនៅសៀមរាបម្ល៉េះ។»

នាងទាញមុខខ្ញុំយកទៅថើប តែខ្ញុំទាញដៃនាងចេញខំគេចពីរឿងមិនសមរម្យនេះ។

## ជីវភាពឯកា

«ស្ទើ! កុំអ៊ីចឹងអី...។»

នាងគ្មានស្តាប់ខ្ញុំសោះ។ មិនដឹងថាមកពីអំណាចស្រា ឬជាគម្រោងអីរបស់នាងទេ។ ខ្ញុំពិតជាពិបាកទ្រាំណាស់នៅពេលដែលស្រីស្អាតក្នុងសម្លៀកសិចស៊ី ឱបកមិនលែង ហើយចេះតែចង់មកថើបខ្ញុំបែបនេះ។

ផ្ទះនៅឯណាក៏មិនដឹង! អស់ជម្រើស ខ្ញុំមានតែដឹកនាងទៅសណ្ឋាគារ...។

គិតដល់ណាហើយ? ខ្ញុំមិនមែនជាមនុស្សប្រុសបែបនោះទេ! ទោះកាលពីយប់មិញពិបាកទ្រាំមែន តែខ្ញុំនៅមានឆន្ទៈជាកូនប្រុសពេញលក្ខណៈ។ ខ្ញុំមិនចង់ប៉ះពាល់នារីដែលខ្ញុំមិនស្រលាញ់នោះទេ ហើយក៏មិនប៉ះពាល់មនុស្សដែលខ្ញុំស្រលាញ់មុនថ្ងៃអាពាហ៍ពិពាហ៍មកដល់ដែរ។

ថ្ងៃនេះការងារច្រើនមែន។ ខ្ញុំធ្វើមិនអស់សោះ។ ភ្លេចខ្លួនក៏ដល់ម៉ោងបាយល្ងាច។ សំឡេងស្បែកជើងកែងចោទស្រួយស្រែសដើរមកដល់មុខតុធ្វើការរបស់ខ្ញុំ។

«បងផានុ!»

«អ្ហ៎ា! រស្មី?»

«បងផានុ! ម៉េចធ្វើការមិនបិទទ្វារបន្ទប់អ៊ីចឹង?»

«អ៎! គឺងាយស្រួលទំនាក់ទំនងបុគ្គលិក។»

«តែពេលនេះមិនចង់ឱ្យបងទំនាក់ទំនងបុគ្គលិកទេ ខ្ញុំសូមបិទទ្វារបន្ទប់មួយភ្លែតសិនណ៎ា។»

ខ្ញុំដូចជាព្រឺសម្បុរនឹងកាយវិការមាយារបស់រស្មី តែសម្រស់ដ៏ទាក់ទាញរបស់នាងធ្វើឱ្យខ្ញុំពិបាកបដិសេធការសុំរបស់នាងណាស់។ រស្មីបិទទ្វារបន្ទប់ ហើយដើរមកកៀកកៅអីដែលខ្ញុំកំពុងអង្គុយ។ នាងឈរបែរមុខមកខ្ញុំដោយផ្អែកខ្លួនទៅតុរបស់ខ្ញុំបន្តិច។ ដៃនាងហ៊ានលូកមកចាប់ដៃខ្ញុំដូចជាមិនមានការអៀនអន់ ដូចពីកាលដែលនាងនៅជាមួយក្រុមមិត្តរបស់នាងនៅប្រទេសសិង្ហបុរីនោះសោះ។ សំពត់ខ្លីរបស់រស្មី ធ្វើឱ្យខ្ញុំពិបាកនឹងសម្លឹងនាងចំខ្លាំងណាស់។

«ស្មី! ចង់ធ្វើអីហ្នឹង?» ខ្ញុំដកដៃពីការអង្អែលរបស់នាង។

«ចុះយប់មិញ?»

«ស្មីកុំយល់ច្រឡំ! ខ្ញុំមិនបានធ្វើអីស្មីទេ!»

«បែបនេះហើយ ទើបខ្ញុំមកអរគុណបង។» នាងសើចហើយដើរទៅអង្គុយកៅអីទល់មុខខ្ញុំយ៉ាងព្រងើយ។

«អ៎! មិនអីទេ...។» ខ្ញុំតបទៅកញ្ញាសិចស៊ីទាំងធូរទ្រូង។

«ខ្ញុំលេងសើចជាមួយបងទេ។ បងកុំគិតផ្ដេសផ្ដាសមកលើខ្ញុំអី។ យប់មិញឱ្យខ្ញុំសុំទោសផងដែលផឹកទាល់តែបាត់ស្មារតី។ សំណាងខ្ញុំណាស់ដែលបងជាបុរសល្អ។»

«បាទ! មិនអីទេ!»

«ខ្ញុំមកនេះដើម្បីអញ្ជើញបងទៅញ៉ាំបាយថ្ងៃត្រង់។ ខ្ញុំចង់អរគុណនិងសុំទោសបង ចំពោះរឿងពីយប់មិញនេះ។»

«អឺ! នែក៎...»

«កុំបដិសេធណា។ តស់ទៅ!» នាងមិនឱ្យខ្ញុំបដិសេធបានឡើយ។ ដៃស្រឡូនមកចាប់ទាញដៃរបស់ខ្ញុំឱ្យងើបដើរទៅតាមការទាមទាររបស់នាង។

រស្មីនិងខ្ញុំចាប់ផ្តើមមានទំនាក់ទំនងស្និទ្ធស្នាលគ្នាពីមួយថ្ងៃទៅមួយថ្ងៃ។ ទំនាក់ទំនងពួកយើងបែបណាខ្ញុំមិនដឹងទេ ខ្ញុំដឹងតែត្រឹមថាបេះដូងរបស់ខ្ញុំតែងតែលោតខុសចង្វាក់ក្រោមភាពស្និទ្ធស្នាលដែលរស្មីផ្តល់ឱ្យ។ ខ្ញុំមិនធ្លាប់បដិសេធការសុំរបស់នាងម្តងណាឡើយ មិនថានាងចង់បានអ្វីឬចង់ទៅណា ខ្ញុំតែងតែកំដរនាង និងព្រមធ្វើតាមចិត្តនាងរហូតមក។

កេសាក្រអូបឈ្ងប់កើយលើស្មាខ្ញុំ នាងនិយាយឡើង៖

«បងផានុ! យើងដល់ណាហើយ?»

«ដល់កំពង់ធំហើយ! ប៉ុន្មានម៉ោងទៀតនឹងទៅដល់សៀមរាបហើយ។»

«ជិះឡានហត់ណាស់បង! ជិះឡានក្រុងអ៊ីចឹងទៀតកាន់តែយូរ។»

«ចុះរស្មីជាអ្នកចង់មែនទេ?»

«ចាំ! តែទៅវិញលែងចង់ហើយ។ បងកក់សំបុត្រយន្តហោះទៅ! មិនអ៊ីចឹងទេ ខ្ញុំរឹងចង្កេះស្លាប់ហើយ។»

ខ្ញុំមិនឆ្លើយ បានត្រឹមតែសើចងក់ក្បាល ដៃអង្អែលសក់រលោងរបស់នាង។ មើលទៅរស្មីដូចជាគេងលក់ស្រួល

ណាស់ ឯខ្ញុំស្ទើកស្មាណាស់ទៅហើយ។ តែមិនអីទេ! បាន ស្រីស្អាតគេងកើយបែបនេះ ស្ពឹកលើសហ្នឹងបន្តិចក៏មិនអីដែរ។

«រស្មីភ្ញាក់ឡើង! យើងមកដល់ហើយណា៎។»

«អ៊ំ! ដល់ហើយអ្ហេ?»

«តស់! ចុះទៅ...។»

«បងផានុ! ទុកតែអីវ៉ាន់ ហើយយើងទៅលេងអង្គរណ៎ា។ ខ្ញុំចង់ទៅញ៉ាំបាយមុខអង្គរ។ ខ្ញុំនឹកទិដ្ឋភាពថ្ងៃលិចមុខប្រាសាទអង្គរណាស់។»

«បាទ! បាទ...»

ទេសភាពថ្ងៃលិចនៅប្រាង្គអង្គរពិតជាស្រស់ស្អាតណាស់។ ខ្ញុំដូចជាខានមកទីនេះយូរហើយ។ ដក់ចិត្តគយគន់អង្គរពណ៌មាសស្ទើរតែភ្លេចញ៉ាំបាយ... ភ្លេចគិតថាខ្ញុំកំពុងមកជាមួយរស្មីទៅហើយ។

«បងផានុ! អណ្តែតអណ្តូងណាស់... មើលតែទេសភាព មិនមើលមុខខ្ញុំផង!»

«បាទ?...» សំឡេងមាយាររបស់រស្មីដាស់ខ្ញុំឱ្យភ្ញាក់ពីការគយគន់ទេសភាពដ៏ស្រស់សោភានេះ។

«នៅអង្គុយហ្នឹងហើយអ៊ីចឹង! ខ្ញុំទៅរើសមាន់អាំងសិនណ៎ា... មិនទុកចិត្តអ្នកលក់ទេ។»

«បាទ!»

ឱកាសនៅម្នាក់ឯង ធ្វើឱ្យខ្ញុំដូចជាមានសេរីភាពផ្លូវចិត្តកាន់តែច្រើន។ អារម្មណ៍របស់ខ្ញុំចាប់ផ្តើមរវើរវាយហោះទៅគ្រប់ទីកន្លែង ពីរឿងមួយទៅរឿងមួយ។ សុខៗខ្ញុំដូចជានឹកឃើញលីណា ព្រោះក៏ធ្លាប់មកទីនេះជាមួយនាង។ លីណាពេលនេះប្រហែលកំពុងរវល់នឹងការងារក្រុមហ៊ុនអាកាសចរណ៍របស់នាងយ៉ាងណាទេ? បន្តិចក៏នឹកដល់អនុស្សាវរីយជាមួយទេពី។ ខ្ញុំខំធ្មេចភ្នែកលេបការឈឺចាប់... បង្ខំអារម្មណ៍ខ្លួនឯងឱ្យគិតអីផ្សេងពីការឈឺចាប់នេះ។

«បងផានុ! ម៉េចធ្វើមុខអ៊ីចឹង?»

«អ៊ំ! មកពីហត់ពេក... ហើយឃ្លានផង។»

«បងញ៉ាំនំផ្លែអាយនេះលេងៗសិនទៅអ៊ីចឹង។ បន្តិចទៀតអ្នកលក់យកមាន់មកតាមក្រោយហើយ។ នុះ! អ្នកលក់កំពុងដើរមកហើយ។»

ខ្ញុំទទួលកន្ទោងនំផ្លែអាយពីដៃរស្មី និងតាមសម្លឹងមើលការចង្អុលនៃម្រាមដៃដ៏ស្រឡូនរបស់នាង។

## ជីវភាពឯកា

«មកដល់ហើយណ៎ា! នេះមាន់អាំងក្តៅៗ... ប្រហុកក៏ឈ្ងុយដែរ... អញ្ជើញគូស្នេហ៍មួយគូនេះញ៉ាំឱ្យមានក្តីសុខចុះណ៎ា។» អ្នកលក់លើកម្ហូបមកដាក់នឹងមុខពួកយើង ក្លែមជាមួយសម្តីឃ្លោងឃ្លាផ្អែមល្ហែមផង។

«សម្តីផ្អែមដល់ហើយអ្នកលក់នេះ!» រស្មីតបទៅអ្នកលក់ទាំងញញឹមខ្ជឹប។

នាងដាក់បង្គុយស្មើរតែលើភ្លៅខ្ញុំដែលកំពុងពែន។ ក្បាលនាងផ្អែកលើស្មាខ្ញុំបន្តិច សម្តែងភាពស្និទ្ធស្នាលផ្អែមល្ហែម។ អ្នកណាដែលបានឃើញក៏គិតថាយើងជាគូស្នេហ៍នឹងគ្នាដែរ។ តាមពិតខ្ញុំមិនដែលហ៊ានប៉ះពាល់រស្មីទេ។ ប៉ុន្តែ... ខ្ញុំក៏ជាប្រុសដែលទប់ចិត្តនឹងសម្រស់នារីដែលល្អធើតដូចរស្មីនេះមិនបានដែរ។ រាល់ពេលដែលនាងមកស្និទ្ធស្នាលនឹងខ្ញុំ ខ្ញុំហាមចិត្តមិនទទួលការស្និទ្ធស្នាលនោះមិនបានទេ។ នាងផ្តល់ភាពស្និទ្ធស្នាលបែបនេះឱ្យខ្ញុំរហូតដល់ខ្ញុំចេះញៀន។ ចិត្តខ្ញុំក៏ចង់ឱ្យនាងមកក្បែរនែបនិត្យខ្ញុំដែរ។

«គិតអីហ្នឹង? អណ្តែតអណ្តូងណាស់! នេះបងញ៉ាំសាច់មាន់នេះទៅ។»

«អរគុណបាទ! រស្មីកុំពិបាកអី ខ្ញុំបេះខ្លួនឯងក៏បាន។»

«មិនអីទេ ប្រឡាក់ដៃតែម្នាក់បានហើយ។ បងផានុញ៉ាំឱ្យច្រើនទៅ! នេះខ្ញុំបញ្ចុកណ៎ា។»

នាងធ្វើមុខម្ញិកម្ញ៉ក់គួរឱ្យស្រលាញ់។ ភាពប៉ិនប្រសប់យកចិត្តយកថ្លើម ដងខ្លួនសិចស៊ីល្វតល្វន់ បត់បែនចុះឡើងធ្វើឱ្យខ្ញុំប្រកែកមិនបាន ត្រូវតែហាមាត់ទទួលដុំបាយដែលនាងពូតបញ្ចុក។

«ឆ្ងាញ់ណាស់ មែនទេ?»

«បាទ! ឆ្ងាញ់ណាស់។»

កែវភ្នែករស្មីស្អាតម្ល៉េះ ពេលដែលនាងសម្លឹងមកខ្ញុំបែបនេះ។ ខ្ញុំចង់និយាយសរសើរនាងណាស់ តែមិនហ៊ានទេ។ ខ្ញុំបានត្រឹមតែសម្លឹងដោយបេះដូងពុះកញ្ជ្រោល។

«បងផានុអ្ហា! យប់នេះយើងទៅក្លឹបទៅ។ ខ្ញុំចង់រាំ។»

«បាទ! រស្មីចង់ទៅក្លឹបមួយណា?»

«មិនដឹងទេ! មួយណាក៏បាន ឱ្យតែបងជូនទៅ។»

«អ៊ីចឹងយើងញ៉ាំឱ្យឆាប់ហើយ បន្ទាប់មកទៅសណ្ឋាគារសម្រាកមួយភ្លែត ចាំរៀបចំខ្លួនទៅក្លឹបរាំលេង។»

«ចា៎! អ៊ីចឹងខ្ញុំឆ្អែតហើយ។»

## ជីវភាពឯកា

រស្មីទម្លាក់បាយម្ហូបពីដៃ ឈប់ញ៉ាំ។ នាងសើចស្ញេញ បញ្ចេញធ្មេញសស្មើស្អាត សមជាមួយថ្ពាល់ខួចទាំងសងខាងផង ធ្វើឱ្យខ្ញុំស្ទើរតែលង់នឹងសម្រស់នាងម្តងៗទៅហើយ។

ម៉ោងកំណត់បានមកដល់ សំឡេងគោះទ្វារបន្ទប់ខ្ញុំឮតឹកតឹក!...

«បងផាន់! បើកទ្វារ...»

«រស្មីទេអ្ហី?»

«នេះម៉ោងប៉ុន្មានហើយ? បងមិនទាន់រៀបចំខ្លួនទៀត?» នាងសួរទាំងមុខក្រញូវ។

«អ៊ំ! ខ្ញុំសុំទោស។ ខ្ញុំគេងជ្រុល។ រស្មីចាំខ្ញុំមួយភ្លែតណ៎ា ... តែបន្តិចរួចហើយ។»

«ខ្ញុំឱ្យពេលបងតែ១៥នាទីទេ។ ខ្ញុំទៅចាំបងនៅសាឡុងទទួលភ្ញៀវខាងក្រោម។»

នាងខឹងហើយ! ខ្ញុំអើយខ្ញុំ! មិនគួរដេកជ្រុលសោះ។ ១៥នាទីរួចជាស្រេច ខ្ញុំទៅប្រាកដខ្លួនពីមុខស្រីស្រស់ដែលកំពុងធ្វើមុខក្រញូវ រំលេចថ្ពាល់ក្រហមគួរឱ្យចង់ថើប។ រស្មីនៅតែបន្តមុខក្រញូវគួរឱ្យចង់ថើបលួងលោម។ តែ... ខ្ញុំមិន

ហ៊ានទេ។ ខ្ញុំបានត្រឹមតែលួចមើលមុខក្រញូវរបស់នាងបណ្តើរ ដោយសង្ឃឹមបន្តិចទៀត នាងនឹងញញឹមស្រស់ស្រាយដូចរាល់ដងវិញ។ ទៅដល់ក្លឹបរកកន្លែងបានអង្គុយ ទើបនាងព្រមស្រដីមកខ្ញុំ។

«បងធ្វើឱ្យខ្ញុំអស់អារម្មណ៍សប្បាយហើយ!»

«ឱ្យខ្ញុំសុំទោសរស្មី... មកពីខ្ញុំអស់កម្លាំងបន្តិច ទើបគេងជ្រុល។ ពេលនេះរស្មីដាក់ទោសមកចុះណ៎ា។»

នាងញញឹមមាត់ក្រប្លួច ដូចជាត្រូវចិត្តនឹងប្រយោគចុងក្រោយរបស់ខ្ញុំ។

ស្របពេលបុគ្គលិកក្លឹបកំពុងដាក់ស្រាបៀរលើតុផងនោះ នាងហុចកែវស្រាបៀរឱ្យមកខ្ញុំ។

«នេះ! បងផឹកឱ្យដាច់ទើបខ្ញុំបាត់ខឹង... មិនឱ្យសល់ទេណ៎ា!»

«បាទបាន! បើខ្ញុំផឹកហើយរស្មីឈប់ធ្វើមុខក្រញូវទៅណ៎ា។»

«ខ្ញុំព្រម!»

## ជីវភាពឯកា

ខ្ញុំលើកស្រាបៀរត្រជាក់ស្រឹបមួយកែវធំផឹកសឹងតែចេញតាមច្រមុះមកវិញ។ ព្រោះតែកែវធំពេក ដកដង្ហើមប៉ិះមិនដល់។

«ខ្ញុំកំដរបងណា៎!»

ពោលមិនដាច់ពីមាត់ នាងលើកកែវស្រាបៀរបស់នាងផឹកតាមក្រោយដែរ។ តែ... នាងញ៉ាំតែពាក់កណ្តាលទេ។

«ម៉េចមិនញ៉ាំឱ្យដាច់ដែរទៅ?»

«មកពីខ្ញុំមិនត្រូវបានពិន័យ!» នាងសើចញាក់មុខឌឺដាក់ខ្ញុំ។

នាងទាញដៃខ្ញុំឱ្យក្រោកឈររាំនៅនឹងតុ... ហើយទាញដៃខ្ញុំឱ្យឱបចង្កេះនាង។ សំពត់រឹបខើចខ្លី អាវស្តើងរលោងសាច់ក្រណាត់ទន់ត្រជាក់ គួរឱ្យចង់អង្អែលអ្វីម្ល៉េះ។ ជាមួយកាយវិការរាំបែបសិចស៊ីរបស់រស្មី ធ្វើឱ្យទាក់ចិត្តកំលោះបេះដូងស្លឹកខ្ញុំនេះម្ល៉េះទេ។ ឱ! ធម្មជាតិមនុស្សប្រុសអើយ! តើខ្ញុំអាចឆ្លងផុតដំណាក់កាលស្រីស្អាតបានឬទេយប់នេះ? រស្មីស្រវឹងជោក ឱបកខ្ញុំមិនលែង។

«ស្មី! មកដល់បន្ទប់ហើយណ៎ា។ លែងខ្ញុំទៅ... ឱ្យខ្ញុំបានទៅបន្ទប់ខ្ញុំវិញ។»

«អត់ទេ! បងនៅគេងទីនេះហើយ...។»

«មិនបានទេ! ស្មីស្រវឹងហើយ...។»

ដោះដៃពីស្រីស្អាតទម្រាំតែបាន ខ្ញុំស្ទើរតែបែកញើសទៅហើយ។ មិនមែនបែកញើសដោយកម្លាំងរើរបស់នាងទេ តែបែកញើសដោយការព្យាយាមឃាត់អារម្មណ៍ខ្លួនឯងទៅវិញទេ។ ស្មីតែងតែប្រើស្នៀតនេះដើម្បីទាញយកទំនាក់ទំនងច្បាស់លាស់មួយជាមួយខ្ញុំ។ ទម្រាំតែរួចខ្លួនបានមកដេកបន្ទប់ខ្លួនឯង វាមិនមែនជារឿងងាយទេ។

ខ្ញុំទើបតែបានធ្មេចមួយស្រទៀត ស្រាប់តែ...

«តឹក! តឹក! តឹក!...»

ចុះអ្នកណាគោះទ្វារអីទាំងកណ្តាលយប់? ខ្ញុំចុះពីគ្រែដេកដើរសំដៅទៅទ្វារបន្ទប់... ខំអើតមើលតាមកញ្ចក់តូចលើទ្វារបន្ទប់... អ្ហាក់! ស្មីទេ? ខ្ញុំបើកទ្វារក្រោក។ ឃើញស្មីភ្លាម កំដៅខ្លួនខ្ញុំឡើងប្រហែលដល់៤០អង្សា... ឈាមចង់ផ្ទុះចេញមកក្រៅ ដោយសារតែរ៉ូបរាត្រីស្តើងមើលឃើញ

ដល់សាច់ខាងក្នុងរបស់នាង។ ខ្ញុំទាញដៃនាងចូលមកក្នុងបន្ទប់ខ្ញុំទាំងកញ្ជក់ ហើយបិទទ្វារ។ បំណងរបស់ខ្ញុំគ្រាន់តែមិនចង់ឱ្យមានអ្នកផ្សេងមកឃើញដងខ្លួនដ៏សិចស៊ីរបស់នាងតែប៉ុណ្ណោះ។

«ស្មី! មានការអីទាំងយប់?»

«គឺ... គឺខ្ញុំ...»

«ស្មី! គឺយ៉ាងម៉េច?»

«ខ្ញុំខ្លាច! ខ្ញុំមិនហ៊ានគេងតែឯង។»

ល្បិច... ល្បិចថ្មីទៀតហើយស្មី! នាងដូចជាតាមចង់ឈ្នះចិត្តព្រះរបស់ខ្ញុំដល់ហើយ។ នាងមិនដឹងទេថាពាល់ដងខ្ញុំទ្រាំខ្លាំងណាស់ ទម្រាំផុតដំណាក់កាលរបស់នាងម្ដងៗ។ ចុះយប់នេះខ្ញុំអាចឆ្លងផុតទេ? មើលទៅស្នៀតរបស់នាងមួយនេះដូចជាខ្លាំងក្លាណាស់។

«ស្មីទៅគេងបន្ទប់ស្មីវិញទៅ! គេងនៅទីនេះមិនសមទេ...។»

«បងផានុ!» នាងហៅឈ្មោះខ្ញុំដោយសំឡេងអួសៗ ហើយនាងហក់ឱបកខ្ញុំជាប់ ទើបបន្ត «ខ្ញុំមិនទៅទេ ... ខ្ញុំខ្លាចមែនណ៎ា។»

«មានអីមែនទេ?» ប្រហែលជានាងបានឃើញអ្វីមិនល្អក្នុងបន្ទប់?

«ចា៎! ខ្ញុំមិនទៅគេងវិញទេ... ឱ្យខ្ញុំគេងទីនេះផង។»

និយាយចប់ នាងអូសដៃខ្ញុំមួយទំហឹងទៅលើគ្រែ ហក់ឱបថើបខ្ញុំតាមតែចិត្តនាង...។

ខ្ញុំឆ្លងដំណាក់កាលស្រីស្អាតមិនរួចទៀតឡើយ... ចុងក្រោយក៏ត្រូវចាញ់នៅក្រោមកណ្ដាប់ដៃរបស់រស្មី។

## ជីវភាពឯកា

ត្រឡប់មកពីខេត្តសៀមរាបវិញ ខ្ញុំនិងរស្មីមិនដូចដើមទេ។ នាងតាមខ្ញុំកាន់តែស្អិត ខ្ញុំកាន់តែគេចពីនាង។ ខ្ញុំពិតជារាងចាលនូវអ្វីដែលបានកើតឡើង ហើយក៏មិនចង់ឱ្យវាកើតបន្តទៀតដែរ។ ដើម្បីឱ្យឆាប់ដាច់ស្រេច ថ្ងៃមួយខ្ញុំក៏ណាត់នាងចេញមកនិយាយតទល់។

«បងផានុ! បងព្រមណាត់ខ្ញុំហើយឬ?»

«បាទ! ខ្ញុំចង់និយាយរឿងខ្លះជាមួយរស្មីឱ្យបានដាច់ស្រេច។»

«ដាច់ស្រេចយ៉ាងម៉េចបង? ពួកយើងទើបតែចាប់ផ្ដើមទេណា។»

«ពួកយើងមិនធ្លាប់ចាប់ផ្ដើមទេរស្មី។»

«ចុះកន្លងមកនោះជាអ្វី?»

«គឺអ្វីដែលរស្មីចង់បាន។»

«ចុះបងមិនចង់បានទេ?»

«ខ្ញុំសុំទោសរស្មី! រស្មីស្អាតហួសនឹងឱ្យធម្មជាតិជាមនុស្សប្រុសអាចប្រកែកអ្វីដែលរស្មីចង់ឱ្យមកនោះបានណាស់។ ខ្ញុំសារភាពខ្ញុំចាញ់សម្រស់ឆើតរបស់រស្មី។ កន្លង

មកនេះខ្ញុំងើបចិត្តមិនរួចនឹងប្រកែកការស្នើសុំរបស់រស្មី ទេ។»

«ចុះពេលនេះបងកំពុងចង់ធ្វើអី? ខ្ញុំមិនយល់ទេ!»

«ខ្ញុំកំពុងតែចង់ប្រាប់រស្មីថា ខ្ញុំមិនធ្លាប់ស្រលាញ់រស្មី ទេ។ សូមកុំឱ្យរស្មីយល់ច្រឡំ។»

«ពេលនេះឬទើបមកប្រាប់? ហេតុអ្វីមិនប្រាប់មុនអ្វីៗ កើតឡើង? បងបានគ្រប់យ៉ាងហើយទើបបងហ៊ាន និយាយការពិតបែបនេះ? នេះឬមនុស្សប្រុស?»

«រស្មី! ខ្ញុំសុំទោស!»

«បងសុំទោស! តែ... អ្វីដែលខ្ញុំបាត់បង់ តើបានអ្នក ណាសង? ខ្ញុំព្រមឱ្យបង... បងគិតថាខ្ញុំងាយមែន ទេ?»

«ខ្ញុំគ្មានបំណងដូច្នេះទេ!»

«ព្រោះខ្ញុំជឿជាក់បង... ទើបខ្ញុំព្រមប្រគល់គ្រប់យ៉ាងឱ្យ បង។ ទីបំផុត... ការលះបង់បានត្រឹមតែឈ្មោះស្រីខ្លួន ងាយ?»

«ខ្ញុំមិនមានបំណងដូច្នោះទេរស្មី! ខ្ញុំដឹងថាខ្ញុំជាមនុស្ស ដំបូងរបស់រស្មី តែ...។»

## ជីវភាពឯកា

«តែបងគ្រាន់តែបណ្ដោយឱ្យខ្ញុំធ្វើគ្រប់យ៉ាងទៅតាមអារម្មណ៍? យកបានគ្រប់យ៉ាងហើយបងក៏ដោះដៃបែបនេះ? ប្រើពាក្យខ្លីៗមកបញ្ចប់មនោសញ្ចេតនាខ្ញុំបែបនេះ... បងមិនបានស្រលាញ់ខ្ញុំទេ?»

រស្មីនិយាយមិនចប់ស្រួលបួលផង នាងខ្ទប់មុខយំរត់ទៅបាត់។ បេះដូងប្រមាត់ខ្ញុំចុកផ្សាអាណិតនាងពេកណាស់ តែការស្រលាញ់បង្ខំមិនបាន។ ជាតិជាប្រុសរបស់ខ្ញុំគឺវាមានមែន។ ខ្ញុំហាមចិត្តមិនបាននឹងសម្រស់ឆើតឆាយរបស់នាងទេ។ បើខ្ញុំមិនអាត្មានិយមបន្តិច នាងនឹងមិនខាតបង់ដល់ម្លឹងទេ។ ពេលនេះតើខ្ញុំគួរធ្វើបែបណាឱ្យនាងស្រាកស្រាន្ត? តែខ្ញុំមិនអាចលះបង់ពេលវេលាទៅធ្វើជាមនុស្សស្រលាញ់នាងទាំងដែលចិត្តមិនស្រលាញ់នាងនោះទេ។ មានតែបណ្ដោយឱ្យនាងឈឺចាប់មួយរយៈ។

សុំទោសរស្មី!!!